**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
# ក្រមសីលធម៌ឱសថការី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧ /០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ ការគោរពច្បាប់ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ ប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរដើម្បីសុខុមាលភាពប្រជាជន។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្រមសីលធម៌វិជ្ជាជីវៈឱសថសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះឱសថការីទាំងអស់ដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈឱសថសាស្ត្រពីក្រសួងសុខាភិបាល។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

**ការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ** សំដៅដល់ការប្រកបវិជ្ជាជីវៈទាក់ទងនឹងការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការទុកដាក់ថែរក្សា ការផលិត ការចែកចាយ អាហរណកម្មនីហរណកម្ម ការត្រួតពិនិត្យគុណភាព ការធ្វើពាណិជ្ជកម្មនិងការផ្សព្វផ្សាយឱសថ ឧបករណ៍បរិក្ខារពេទ្យ ប្រតិករផលិតផលគ្រឿងសម្អាង និងការប្រកបវិជ្ជាជីវៈទាក់ទងនឹងមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ។

**ការផ្តល់ឱសថ** សំដៅដល់សកម្មភាពផ្តល់ឱសថដោយមានការពន្យល់ច្បាស់លាស់ដល់អ្នកជំងឺឬអតិថិជន។

**គ្រឹះស្ថានឱសថ** សំដៅដល់កន្លែងដែលឱសថការីបម្រើការងារឬទទួលខុសត្រូវ ដូចជាគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ គ្រឹះស្ថានលក់ដុំឱសថ ឱសថស្ថាននិងឱសថស្ថានរង។

**ឱសថការី** សំដៅដល់នីតិជនដែលមានសញ្ញាបត្រឱសថសាស្ត្រ ចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រឱសថសាស្ត្រ ចេញដោយគ្រឹះស្ថានឧត្តមសិក្សាដែលបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

## ជំពូកទី២

## ករណីយកិច្ចទូទៅរបស់ឱសថការី

**មាត្រា៥ .-**

ឱសថការីត្រូវប្រកាន់ខ្ជាប់នូវករណីយកិច្ចការពារសុខភាពសាធារណៈដោយត្រូវគោរពជីវិតរាងកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

**មាត្រា៦ .-**

ឱសថការីត្រូវប្រកាន់ខ្ជាប់នូវឯករាជ្យភាពវិជ្ជាជីវៈ និងត្រូវធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រ ដោយគោរពដាច់ខាតនូវសុចរិតភាព ភក្តីភាពនិងឯករាជ្យភាពវិជ្ជាជីវៈ ដោយគ្មានការបង្ខិតបង្ខំពីខាងក្រៅ ទោះបីជាស្ថិតក្នុងលក្ខខណ្ឌបែបណាក៏ដោយ។

**មាត្រា៧ ..**

ឱសថការីត្រូវតែចូលរួមរាល់សកម្មភាពដែលតម្រូវដោយអាជ្ញាធរសុខាភិបាលដើម្បីសុខុមាលភាពប្រជាជននិងសង្គម។

**មាត្រា៨ ..**

ទោះក្នុងរូបភាពអ្វីក៏ដោយ ឱសថការីមិនត្រូវបង្កនូវអំពើដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈឡើយ។ ឱសថការីត្រូវចូលរួមប្រឆាំងនឹងអំពើនបោក ពិសេសត្រូវជៀសវាងផលិត ចែកចាយ និងធ្វើអាជីវកម្មនូវផលិតផលឱសថក្លែងក្លាយនិងអន់គុណភាព ហួសកំណត់ពេលប្រើប្រាស់ ឬមិនឱ្យប្រើប្រាស់។

**មាត្រា៩ ..**

ឱសថការីត្រូវផ្តល់ដំណឹងជូនគណៈឱសថការីកម្ពុជាអំពីការបើក ការបិទ ការប្តូរទីតាំង ការប្តូរឱសថការីទទួលខុសត្រូវ ការប្តូរមូលនិធិឬម្ចាស់ទុន ការផ្អាកឬការឈប់ប្រកបអាជីវកម្ម ឬការឈប់ទទួលខុសត្រូវគ្រឹះស្ថានឱសថ។

**មាត្រា១០ ..**

នៅពេលសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ឱសថការីត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរថាខ្លួនបានអានក្រមសីលធម៌ឱសថការី និងសន្យាគោរពប្រតិបត្តិតាម។

**មាត្រា១១ ..**

ឱសថការីត្រូវចូលរួមក្នុងសកម្មភាពវិជ្ជាជីវៈដែលរៀបចំដោយគណៈឱសថការីកម្ពុជា។

**មាត្រា១២ ..**

ឱសថការីដែលគ្រប់គ្រងគ្រឹះស្ថានឱសថឬមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ ត្រូវរៀបចំទីកន្លែងទាំងខាងក្រៅ ទាំងខាងក្នុង ឱ្យសមស្របទៅតាមបទដ្ឋានបច្ចេកទេស ដើម្បីធានាការបម្រើនិងការផ្តល់សេវាសមស្របប្រកបដោយគុណភាព។

**មាត្រា១៣ ..**

ឱសថការីត្រូវបំពេញគ្រប់សកម្មភាពនៃវិជ្ជាជីវៈដោយយកចិត្តទុកដាក់និងប្រុងប្រយ័ត្នជានិច្ចដោយគោរពឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិនិងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈឱសថសាស្ត្រ។ ទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ឱសថការីត្រូវប្រកាន់ឥរិយាបថទៀងត្រង់និងថ្លៃថ្នូរ។ ឱសថការីត្រូវជៀសវាងរាល់អំពើទាំងឡាយណាដែលនាំឱ្យអាប់ឱនដល់វិជ្ជាជីវៈរបស់ខ្លួន ទោះបីជាមិនស្ថិតក្នុងពេលបំពេញមុខងារវិជ្ជាជីវៈឱសថសាស្ត្រក៏ដោយ។

**មាត្រា១៤ ..**

ឱសថការីមានកាតព្វកិច្ចលើកកម្ពស់ចំណេះដឹងផ្នែកឱសថសាស្ត្រ ធ្វើឱ្យកាន់តែសុក្រឹតនូវចំណេះវិជ្ជារបស់ខ្លួនស្របតាមបច្ចុប្បន្នភាពនៃការវិវឌ្ឍបច្ចេកទេសវិទ្យាសាស្ត្រ ពិសេសត្រូវចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលបន្តក្នុងវិស័យសុខាភិបាល ដែលទទួលស្គាល់ដោយគណៈឱសថការីកម្ពុជា។

**មាត្រា១៥ ..**

រាល់ការចុះកិច្ចសន្យា កិច្ចព្រមព្រៀងការងារ ឬអនុសញ្ញារួមនៃការងារជាមួយសមាគម ដៃគូអភិវឌ្ឍ និងអង្គភាពផលិតកម្ម ពាណិជ្ជកម្ម ផ្សព្វផ្សាយឬព័ត៌មានឱសថ ចែកចាយឱសថ និងអ[illegible] សុខភាពជាដើម ឱសថការី ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា១៦ ..**

ឱសថការីមិនត្រូវទទួលប្រាក់រង្វាន់ការងារ បើការទទួលប្រាក់រង្វាន់នោះធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យក្នុងការអនុវត្តការងាររបស់ខ្លួនទាក់ទងនឹងគុណភាពឱសថឬដល់គុណភាពនៃសេវា។ ការទទួលយកឬស្នើសុំ ឬដាក់កំហិតនូវលាភការដោយមិនសមាមាត្រទៅនឹងទំហំការងារនិងការទទួលខុសត្រូវរបស់ខ្លួនត្រូវបានហាមឃាត់។

**មាត្រា១៧ ..**

ឱសថការីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់សកម្មភាពទាំងឡាយណាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ទោះបីជាសកម្មភាពនោះប្រព្រឹត្តដោយសហការីរបស់ខ្លួនក៏ដោយ និងត្រូវធ្វើយ៉ាងណាឱ្យបុគ្គលិកក្រោមឱវាទគោរពតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងកាតព្វកិច្ចនិងករណីយកិច្ច ដែលមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា១៨ ..**

នៅតាមគ្រឹះស្ថានឱសថ ឱសថការីដែលជាអ្នកគ្រប់គ្រងត្រូវធានាថាឱសថការីជំនួយការឬឱសថការីជំនួសបានចុះឈ្មោះក្នុងបញ្ជីគណៈឱសថការី។ ឱសថការីជំនួយការឬឱសថការីជំនួស និងបុគ្គលិកក្រោមឱវាទទាំងអស់ ត្រូវមានការលះបង់ដោយភក្តីភាពក្នុងការងារ។

**មាត្រា១៩ ..**

ឱសថការីដែលបម្រើការក្នុងគ្រឹះស្ថានឱសថនិងមន្ទីរពិសោធន៍អមវេជ្ជសាស្ត្ររបស់រដ្ឋឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលសម្រាប់ការធ្វើកម្មសិក្សា ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម៖

- មានពេលវេលាគ្រប់គ្រាន់ជួយបង្ហាត់បង្ហាញ
- មានមូលដ្ឋានអនុវត្តរួមនិងសកម្មភាពជាក់ស្តែងសម្រាប់ការបង្ហាត់បង្ហាញ
- ណែនាំនិស្សិតឱ្យយល់អំពីតម្លៃវិជ្ជាជីវៈនិងការគោរពក្រមសីលធម៌
- ណែនាំនិស្សិតឱ្យស្វែងយល់និងគោរពកាតព្វកិច្ចទាំងឡាយដូចគ្នានឹងឱសថការីរបស់គ្រឹះស្ថាន
- វាយតម្លៃនិស្សិតដែលធ្វើកម្មសិក្សាដោយសុចរិតនិងមានមូលដ្ឋានត្រឹមត្រូវ។

**មាត្រា២០ ..**

ឱសថការីគួរប្រើទុនផ្ទាល់ខ្លួនក្នុងការប្រកបសេវាកម្មឬអាជីវកម្មឱសថនិងសេវាកម្មអមវេជ្ជសាស្ត្រជាជាងការទទួលខុសត្រូវផ្នែកបច្ចេកទេសឱ្យម្ចាស់ទុន។

**មាត្រា២១ ..**

ឱសថការីត្រូវតែគោរពតាមគោលការណ៍នៃការអនុវត្តល្អដែលបានកំណត់សម្រាប់ផ្នែកវិជ្ជាជីវៈនីមួយៗ និងមិនត្រូវឱ្យធ្លាក់ទៅក្នុងឧបាយកលពាណិជ្ជកម្មដែលនាំឱ្យប៉ះពាល់កិត្យានុភាពវិជ្ជាជីវៈឱសថសាស្ត្រនោះឡើយ។

**មាត្រា២២ ..**

ឱសថការីត្រូវចូលរួមនិងលើកកម្ពស់កសាងប្រព័ន្ធបរិស្ថានល្អ ដោយជៀសវាងរាល់ទង្វើដែលបង្កឱ្យខូចបរិស្ថាន ពិសេសត្រូវចូលរួមក្នុងសកម្មភាពប្រមូលនិងបំផ្លាញចោលឱសថក្លែងក្លាយ ខូចគុណភាព អន់គុណភាព ហួសកំណត់ពេលប្រើប្រាស់ ឬមិនឱ្យប្រើប្រាស់។

**មាត្រា២៣ .-**

ឱសថការីត្រូវរក្សាទំនាក់ទំនងល្អ ដោយការជឿទុកចិត្តជាមួយភ្នាក់ងារមានសមត្ថកិច្ច និងត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចឬបេសកកម្មរបស់ភ្នាក់ងារត្រួតពិនិត្យឱសថឬអធិការកិច្ចឱសថ។

## ជំពូកទី៣

## ករណីយកិច្ចដោយឡែករបស់ឱសថការី

**មាត្រា២៤ .-**

ឱសថការីមានសិទ្ធិទទួលខុសត្រូវគ្រប់គ្រងបច្ចេកទេស ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្របានតែមួយកន្លែងគត់។

ការប្រកបវិជ្ជាជីវៈឱសថសាស្ត្រមានវិសមិតភាពជាមួយនឹងការប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត ទោះបីជាឱសថការីមានសញ្ញាបត្រវិជ្ជាជីវៈនោះក៏ដោយ។

**មាត្រា២៥ .-**

ឱសថការីត្រូវរៀបចំផ្លាកនិងឈ្មោះឱសថស្ថានឱ្យបានសមរម្យនិងងាយយល់សម្រាប់អតិថិជន។ នៅលើផ្លាកត្រូវមានឈ្មោះអ្នកទទួលខុសត្រូវនិងអាសយដ្ឋាន។

**មាត្រា២៦ .-**

សកម្មភាពពិនិត្យ ពិគ្រោះ ព្យាបាលជំងឺនៅក្នុងឱសថស្ថាន ព្រមទាំងការដាក់ផ្លាកពិនិត្យ ព្យាបាលនៅឱសថស្ថាន ត្រូវបានហាមឃាត់។

**មាត្រា២៧ .-**

ឱសថការីមានកាតព្វកិច្ចៈ

- មានវត្តមាននៅឱសថស្ថានក្នុងម៉ោងធ្វើការឬក្នុងម៉ោងដែលតម្រូវដោយក្រសួងសុខាភិបាល ឬគណៈឱសថការី
- រកអ្នកជំនួសតាមច្បាប់កំណត់ក្នុងករណីអវត្តមាននៅឱសថស្ថាន
- ត្រូវចូលរួមក្នុងកម្មវិធីយាមយប់និងថ្ងៃឈប់សម្រាករបស់ឱសថស្ថាន ដែលរៀបចំឡើងដោយមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬក្រុមប្រឹក្សាគណៈឱសថការីរាជធានី ខេត្ត
- គោរពតាមគោលការណ៍និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលបានកំណត់សម្រាប់ឱសថស្ថានយាម
- ផ្សព្វផ្សាយឱ្យសាធារណជនបានដឹងអំពីកម្មវិធីឱសថស្ថានយាម។

**មាត្រា២៨ .-**

អ្នកគ្រប់គ្រងឱសថស្ថានរបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការ ត្រូវតែជាឱសថការីដែលបានចុះឈ្មោះក្នុងបញ្ជីសមាជិកគណៈឱសថការីកម្ពុជា។

ឱសថការីដែលបម្រើការងារនៅក្នុងឱសថស្ថានរបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការ បម្រើតែសេវារបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការខ្លួនតែប៉ុណ្ណោះ។

**មាត្រា២៩ .-**

ឱសថការីគ្រប់គ្រងឱសថស្ថានរបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការ មានភារកិច្ចធានាលើការផ្គត់ផ្គង់ ការផ្សំឱសថ ការទុកដាក់ ការត្រួតពិនិត្យ និងការចែកចាយផលិតផលសុខាភិបាល ព្រមទាំងប្រើប្រាស់

ការងារទាក់ទងនឹងគុណភាព សុវត្ថិភាពនៃការព្យាបាល ការសិក្សាគ្លីនិក ការតាមដានអំពីផលរំខានរបស់ឱសថ និងការប្រមូលឱសថដែលខូចគុណភាពពីទីផ្សារ។

**មាត្រា៣០.-**

ឱសថការីត្រូវផ្តល់ឱសថដោយគោរពតាមវេជ្ជបញ្ជាឬតាមសំណើរបស់អ្នកជំងឺ ដោយគិតពីផលប្រយោជន៍នៃសុខភាពជាចម្បង និងត្រូវប្រាប់អ្នកជំងឺឱ្យទៅពិគ្រោះជាមួយគ្រូពេទ្យក្នុងករណីចាំបាច់។ ឱសថការីត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាកុំឱ្យយកស្ថានភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបុគ្គលិកលក្ខណៈនៃអ្នកជំងឺឬប្រភេទនៃឱសថជាឧបសគ្គក្នុងការផ្តល់ឱសថ។

**មាត្រា៣១.-**

ក្នុងករណីចាំបាច់ឬពេលយាម ឱសថការីអាចផ្តល់ឱសថដែលអាចជំនួសគ្នាបានដល់អតិថិជនដោយគោរពតាមបទវិធានទាំងឡាយស្តីពីការផ្តល់ឱសថជំនួស។

**មាត្រា៣២.-**

ឱសថការីត្រូវតែពិភាក្សាជាមួយគ្រូពេទ្យដែលចេញវេជ្ជបញ្ជាជាមុនសិន នៅពេលមានចម្ងល់ឬសង្ស័យលើវេជ្ជបញ្ជាមិនច្បាស់លាស់អំពីឈ្មោះឬប្រភេទឱសថ របៀបឬកម្រិតប្រើ ផលរំខាន ឬភាពងាយមានប្រតិកម្មបណ្តាលពីឱសថឬអន្តរកម្មឱសថ។

**មាត្រា៣៣.-**

ឱសថការីត្រូវធានាលើសកម្មភាពផ្តល់ឱសថដល់អ្នកជំងឺ ដោយផ្សារភ្ជាប់៖

- ការវិភាគឱសថលើវេជ្ជបញ្ជា
- ការរៀបចំឱសថសម្រាប់អ្នកជំងឺឱ្យសមស្របតាមគោលការណ៍អនុវត្តល្អក្នុងឱសថស្ថានដែលកំណត់ដោយក្រសួងសុខាភិបាល
- ផ្តល់ព័ត៌មាននិងដំបូន្មានចាំបាច់សម្រាប់ការប្រើប្រាស់ឱសថបានត្រឹមត្រូវ ដូចជាប្រសិទ្ធភាព ការហាមប្រើ ផលរំខាន ប្រការគួរយកចិត្តទុកដាក់ កម្រិតប្រើដោយការពន្យល់នេះមិនធ្វើឱ្យប៉ះពាល់ដល់ការជឿទុកចិត្តទៅលើគ្រូពេទ្យសាមីឡើយ។

**មាត្រា៣៤.-**

ក្នុងករណីដែលអ្នកជំងឺប្រើឱសថដោយចិត្តឯង ឱសថការីត្រូវជំទាស់ទៅនឹងការរំលោភលើការប្រើឱសថ ហើយត្រូវប្រាប់អ្នកជំងឺអំពីផលវិបាកអវិជ្ជមាននិងណែនាំឱ្យទៅពិគ្រោះជាមួយគ្រូពេទ្យក្នុងករណីចាំបាច់។

**មាត្រា៣៥.-**

ក្នុងក្របខ័ណ្ឌនៃការគោរពសិទ្ធិនិងផលប្រយោជន៍អ្នកជំងឺ ឱសថការីត្រូវពន្យល់ ផ្តល់ដំបូន្មានចំពោះឱសថណាដែលខ្លួនយល់ដឹង។ ដើម្បីស្វែងយល់លើឱសថណាមួយ ឱសថការីមិនត្រូវពឹងផ្អែកតែទៅលើឯកសារចេញពីគ្រឹះស្ថានផលិតឱសថឡើយ។

**មាត្រា៣៦.-**

ឱសថការីត្រូវទទួលខុសត្រូវនិងធានាចំពោះការចែកចាយឱសថដោយខ្លួនឯងឬដោយបុគ្គលជំនួយ ដោយបំពេញឱ្យបានត្រឹមត្រូវតាមគោលការណ៍នៃការអនុវត្តល្អក្នុងការផ្តល់ឱសថ។

**មាត្រា៣៧ .-**

ផ្លាកមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រឯកជន ត្រូវមានឈ្មោះឱសថការីដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងបច្ចេកទេស។

**មាត្រា៣៨ .-**

ឱសថការីនៃមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ មិនត្រូវធ្វើការវិភាគដែលមិនចាំបាច់ដើម្បីទាញប្រយោជន៍ពីអតិថិជនឡើយ។ ឱសថការីនៃមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ អាចបដិសេធដោយមានការពន្យល់ មិនធ្វើការវិភាគឬសម្រង់វត្ថុវិភាគ ប្រសិនបើនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អតិថិជន ឬសំណើសុំវិភាគឬសម្រង់វិភាគនោះមានលក្ខណៈខុសច្បាប់។

**មាត្រា៣៩ .-**

ការផលិត ការនាំចូល ការនាំចេញ ការលក់ដុំឱសថ ឧបករណ៍បរិក្ខារពេទ្យ និងប្រតិករ ដែលប្រព្រឹត្តនៅក្នុងឬតាមរយៈគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ និងគ្រឹះស្ថានលក់ដុំឱសថ ត្រូវតែស្ថិតក្រោមការទទួលខុសត្រូវរបស់ឱសថការី។

**មាត្រា៤០ .-**

ការលក់ដុំឱសថ ឧបករណ៍បរិក្ខារពេទ្យ និងប្រតិករដល់សេវាសុខាភិបាលដែលគ្មានច្បាប់អនុញ្ញាត ឬការចែកចាយមិនត្រឹមត្រូវតាមប្រព័ន្ធដែលកំណត់ដោយក្រសួងសុខាភិបាលឬដោយគណៈឱសថការីកម្ពុជា ត្រូវបានហាមឃាត់ជាដាច់ខាត។

**មាត្រា៤១ .-**

ឱសថការីត្រូវជ្រើសរើសយកដៃគូផ្គត់ផ្គង់ឱសថ ឧបករណ៍បរិក្ខារពេទ្យ និងប្រតិករ ដោយគិតអំពីគុណភាពសេវានិងនិរន្តរភាពនៃការផ្គត់ផ្គង់។

**មាត្រា៤២ .-**

ឱសថការីគ្រប់គ្រងគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ និងគ្រឹះស្ថានលក់ដុំឱសថ ជាអ្នកទទួលខុសត្រូវលើរាល់បញ្ហាបច្ចេកទេសទាក់ទងនឹងសកម្មភាពនៃគ្រឹះស្ថាននោះ រួមមានការផលិត ការចែកចាយ ការផ្សព្វផ្សាយផលិតផល ការតាមដានផលរំខានពីឱសថ ការដកហូតឱសថពីទីផ្សារ ការនាំចូលនាំចេញ ការរក្សាទុកក្នុងឃ្លាំង ជាដើម។

**មាត្រា៤៣ .-**

ឱសថការីដែលបានយល់ព្រមប្រកបវិជ្ជាជីវៈក្រោមកិច្ចសន្យាឬមានលក្ខខណ្ឌជាមួយស្ថាប័នរដ្ឋ អង្គការជាតិឬអន្តរជាតិ ឬគ្រឹះស្ថានឯកជនឬសមូហភាពណាមួយ ត្រូវប្រកាន់យកការរក្សាការសម្ងាត់ និងឯករាជ្យភាពវិជ្ជាជីវៈ។

ឱសថការីមិនត្រូវទទួលឬមិនត្រូវបានបង្ខំឱ្យទទួលការដាក់កម្រិតទៅលើឯករាជ្យភាពក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនពីសំណាក់រូបវន្តបុគ្គល នីតិបុគ្គល ឬពីអង្គភាពដែលជានិយោជករបស់ឱសថការីនោះឡើយ។ ឱសថការីត្រូវបំពេញការងារដោយឱ្យអាទិភាពទៅលើផលប្រយោជន៍សុខភាព[illegible]

ព្រមទាំងទៅលើផលប្រយោជន៍និងសុវត្ថិភាពរបស់អ្នកធ្វើការនៅក្នុងសមូហភាពឬអង្គការដែលឱសថការីនោះប្រកបមុខរបរ។

**មាត្រា៤៤ ..**

ការប្រកបវិជ្ជាជីវៈឱសថសាស្ត្រទោះបីជាស្ថិតក្រោមរូបភាពអ្វីនៅឱសថស្ថាន សហគ្រាស សមូហភាព អង្គការដែលស្ថិតក្រោមសមត្ថកិច្ចនៃច្បាប់ស្តីពីការងារក៏ដោយ ត្រូវតែធ្វើឡើងក្រោមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យានេះត្រូវកំណត់ច្បាស់លាស់អំពីភាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនិងត្រូវអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវផ្ញើជូនគណៈឱសថការីកម្ពុជាមួយច្បាប់ដើម្បីជ្រាប និងតម្កល់ទុកជាឯកសារ។

**មាត្រា៤៥ ..**

ឱសថការីដែលមានប្រាក់បៀវត្ស មិនអាចទទួលប្រាក់រង្វាន់ដោយសម្អាងលើបទដ្ឋានផលិត ឬទិន្នផលផលិតកម្មឬសេវា ឬកិច្ចចាត់ចែងផ្សេងទៀតដែលបណ្តាលឱ្យបាត់បង់ឯករាជ្យភាពនិងគុណភាពវិជ្ជាជីវៈ ឬធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃផលិតផលឬសេវា និងមានបច្ច័យមិនល្អចំពោះសុខភាពសាធារណៈឡើយ។

**មាត្រា៤៦ ..**

ការអប់រំ ឬការផ្តល់ព័ត៌មានទូទៅ ឬការផ្សព្វផ្សាយផលិតផលឱសថជាសាធារណៈ ដោយឱសថការី ទោះបីជាក្រោមរូបភាពណាក៏ដោយ ត្រូវស្របតាមបទដ្ឋានបច្ចេកទេស ដោយឡែកការផ្សព្វផ្សាយផលិតផលឱសថ ត្រូវតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

**មាត្រា៤៧ ..**

នៅពេលផ្តល់ព័ត៌មានឬអប់រំផ្សព្វផ្សាយទាក់ទងនឹងឱសថឬសុខភាពសាធារណៈ ឱសថការីត្រូវតែមានសម្អាងហេតុផលច្បាស់លាស់។ ឱសថការីត្រូវជៀសវាងការនិយាយឃោសនាជាប្រយោជន៍ផ្ទាល់ខ្លួនឬប្រយោជន៍គ្រឹះស្ថានដែលខ្លួនធ្វើការឬខ្លួនគាំទ្រ ឬសម្រាប់មូលហេតុអ្វីមួយដែលមិនមែនជាផលប្រយោជន៍សាធារណៈ ដោយប្រុងប្រយ័ត្នទៅលើប្រតិឃាតនៃពាក្យសម្តីរបស់ខ្លួនចំពោះអ្នកស្តាប់។

**មាត្រា៤៨ ..**

ឱសថការីដែលធ្វើការចែកចាយក្នុងបំណងផ្សព្វផ្សាយដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬគ្រឹះស្ថានដែលខ្លួនគាំទ្រនូវផលិតផលឱសថ ដែលមិនទាន់មានច្បាប់អនុញ្ញាតត្រឹមត្រូវ ត្រូវបានហាមឃាត់ ទោះបីជាការចែកចាយនោះមានប្រយោជន៍ដល់សុខភាពក៏ដោយ។

**មាត្រា៤៩ ..**

នៅពេលធ្វើបទបង្ហាញឬផ្សព្វផ្សាយឱសថ ឱសថការីត្រូវមានមូលដ្ឋានច្បាស់លាស់ក្នុងការផ្តល់ព័ត៌មានវិទ្យាសាស្ត្រដែលទាក់ទងនឹងវេជ្ជសាស្ត្រ ឱសថសាស្ត្រ ព្រមទាំងភាពត្រឹមត្រូវនៃការប្រើប្រាស់ឱសថ ជៀសវាងការបំភ័ន្តឬបំផ្លើស។

**មាត្រា៥០ ..**

ឱសថការីត្រូវជៀសវាងការស្វះស្វែងទាក់ទាញអតិថិជន ដោយប្រើប្រាស់មធ្យោបាយដែលនាំឱ្យបាត់បង់កិត្តិយសនិងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ បើទោះបីជាមធ្យោបាយទាំងនោះមិនត្រូវបានប[illegible] ច្បាស់លាស់ដោយបទប្បញ្ញត្តិជាធរមានក៏ដោយ ។

ឱសថការីត្រូវជៀសវាងរាល់ការប្រកួតប្រជែងមិនស្មោះត្រង់។

**មាត្រា៥១.-**

ការផ្សព្វផ្សាយឱសថដោយឱសថការីត្រូវប្រព្រឹត្តទៅដោយភាពថ្លៃថ្នូរ គោរពផលប្រយោជន៍អ្នកជំងឺ ទៅតាមវិធាននៃការផ្សព្វផ្សាយ និងជៀសវាងប្រើមធ្យោបាយអូសទាញឱ្យប្រើឱសថ។

**មាត្រា៥២.-**

ហាមឃាត់ចំពោះឱសថការីក្នុងការផ្តល់រង្វាន់លាភការដល់ជនណាដែលប្រកបវិជ្ជាជីវៈឱសថ-សាស្ត្រឬវេជ្ជសាស្ត្រ ឬវិជ្ជាជីវៈសុខាភិបាលដទៃទៀត ដើម្បីលើកទឹកចិត្តឬជំរុញឱ្យប្រើឱសថ។

**មាត្រា៥៣.-**

ឱសថការីមិនត្រូវរារាំងអតិថិជនក្នុងការជ្រើសរើសគ្រឹះស្ថានសេវាកម្ម ឬអាជីវកម្មឱសថ ឬសេវាកម្មអមវេជ្ជសាស្ត្រណាដែលអតិថិជនពេញចិត្តនោះឡើយ។

ឱសថការីមិនត្រូវសម្រួលឱ្យអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលខុសច្បាប់ណាម្នាក់ឬសម្រួលឱ្យអ្នកជំងឺនូវផលប្រយោជន៍ដែលជាអំពើខុសច្បាប់ ដូចជាការបង្កើនតម្លៃក្នុងវិក្កយបត្រ ឬការចេញសេចក្តីបញ្ជាក់តម្រូវចិត្តអ្នកជំងឺ។

**មាត្រា៥៤.-**

ឱសថការីដែលមានមុខងារក្នុងតំណែងគ្រប់ប្រភេទឬគោរមងារជាកិត្តិយសផ្សេងៗ មិនត្រូវប្រើឈ្មោះនៃមុខងារឬគោរមងារនៃកិត្តិយសនោះ ដើម្បីបង្អួតឬទាក់ទាញស្វែងរកអតិថិជនឡើយ។ ក្នុងការធ្វើអាជីវកម្មឱសថឬសេវាកម្មអមវេជ្ជសាស្ត្រ ឱសថការីអាចប្រើឈ្មោះរបស់ខ្លួន ដោយភ្ជាប់ពាក្យជាមុខងារបច្ចេកទេសវិជ្ជាជីវៈដែលទទួលបានពីគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល។

**មាត្រា៥៥.-**

ឱសថការីត្រូវអនុវត្តតាមសន្ទស្សន៍កម្រៃដែលកំណត់ដោយក្រសួងសុខាភិបាលឬដោយគណៈឱសថការីកម្ពុជា។ ការអនុវត្តទាំងឡាយណាដែលមាននិន្នាការបញ្ចុះតម្លៃឱសថក្នុងបំណងប្រកួតប្រជែង ត្រូវបានហាមឃាត់ ប៉ុន្តែឱសថការីមានសិទ្ធិក្នុងការផ្តល់ឱសថដោយមិនយកថ្លៃ។

**មាត្រា៥៦.-**

ឱសថការីដែលទទួលបន្ទុកត្រួតពិនិត្យនិងអធិការកិច្ចវិជ្ជាជីវៈឱសថសាស្ត្រ ត្រូវស្ថិតនៅក្នុងភាព-ឯករាជ្យនៃមុខងារ និងមិនត្រូវបានអនុញ្ញាតឱ្យត្រួតពិនិត្យនិងធ្វើអធិការកិច្ចចំពោះគ្រឹះស្ថានផ្ទាល់ខ្លួន ឬគ្រឹះស្ថានជារបស់សហព័ទ្ធ ឬជារបស់ញាតិលោហិតផ្ទាល់ ឬជារបស់ញាតិពន្ធនៅក្នុង៣(បី)ថ្នាក់រាប់ទាំងថ្នាក់ទី៣(បី)ផង ឬគ្រឹះស្ថានដែលមានទំនាក់ទំនងការងារឬផលប្រយោជន៍ជាមួយនឹងឱសថការីកំពុងជាប់ពាក់ព័ន្ធឡើយ។

**មាត្រា៥៧.-**

ឱសថការីទទួលបន្ទុកត្រួតពិនិត្យនិងអធិការកិច្ចត្រូវ ៖

- បញ្ជាក់ប្រាប់ដល់តំណាងនៃអង្គភាពដែលខ្លួនត្រួតពិនិត្យអំពីបេសកកម្មនិងអំពីក្របខណ្ឌច្បាប់និងព្រំដែនកំណត់ដែលបេសកកម្មនេះត្រូវអនុវត្ត
- បំពេញភារកិច្ចមិនលម្អៀងក្នុងការធ្វើសេចក្តីសន្និដ្ឋាន។

- រក្សាការសម្ងាត់ដោយមិនត្រូវធ្វើអត្ថាធិប្បាយជាសាធារណៈអំពីបេសកកម្មរបស់ខ្លួន។

## ជំពូកទី៤
## ករណីយកិច្ចចំពោះអ្នកជំងឺនិងអតិថិជន

**មាត្រា៥៨ .-**

ឱសថការីត្រូវប្រកាន់ខ្ជាប់នូវអាកប្បកិរិយាត្រឹមត្រូវនិងយកចិត្តទុកដាក់ចំពោះអ្នកជំងឺនិងអតិថិជន ដោយគ្មានការរើសអើង និងត្រូវខិតខំពន្យល់ឲ្យអនុវត្តតាមវេជ្ជបញ្ជាដើម្បីឱ្យការព្យាបាលមានប្រសិទ្ធភាព។ ឱសថការីត្រូវគោរពសិទ្ធិរបស់អ្នកជំងឺក្នុងការជ្រើសរើសឱសថស្ថាននិងគោរពឆន្ទៈរបស់អ្នកជំងឺក្នុងការទិញឱសថ។

**មាត្រា៥៩ .-**

នៅចំពោះមុខគ្រោះអាសន្នដែលមានអ្នកជំងឺ ឬអ្នករបួស ឬអ្នករងគ្រោះដោយថាហេតុ ឱសថការីត្រូវយកអស់មធ្យោបាយនិងការយល់ដឹងរបស់ខ្លួនជួយអ្នកទាំងនោះ តាមការដែលអាចធ្វើទៅបាន។

**មាត្រា៦០ .-**

ឱសថការីត្រូវរួសរាយរាក់ទាក់ចំពោះអ្នកជំងឺនិងអតិថិជន ស្តាប់យោបល់ឬសំណូមពររបស់អ្នកទាំងនោះ និងត្រូវសម្រួលឱ្យមានការសន្ទនាបែបលាក់បាំង ព្រមទាំងរក្សាការសម្ងាត់របស់អ្នកជំងឺ។ សេចក្តីពន្យល់របស់ឱសថការីទៅអ្នកជំងឺនិងអតិថិជនត្រូវប្រាកដប្រជា ត្រឹមត្រូវ មិនហួសហេតុ និងងាយយល់។

**មាត្រា៦១ .-**

ឱសថការីត្រូវរក្សាការសម្ងាត់ក្នុងវិជ្ជាជីវៈ ដោយគោរពសីលធម៌ គោរពសេចក្តីអៀនខ្មាសនិងការសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកជំងឺ។

ឱសថការីមិនត្រូវនិយាយការសម្ងាត់ដែលខ្លួនបានដឹងឬបានឃើញពាក់ព័ន្ធនឹងរោគវិនិច្ឆ័យឬវេជ្ជបញ្ជា ឬឯកសាររបស់អ្នកជំងឺ ចំពោះមុខតតិយជនឬសាធារណជនឡើយ លើកលែងតែច្បាប់អនុញ្ញាតឬតម្រូវឱ្យបង្ហាញអាថ៌កំបាំង។

**មាត្រា៦២ .-**

ឱសថការីត្រូវខិតខំធ្វើយ៉ាងណាឱ្យអ្នកជំងឺទទួលបាននូវអត្ថប្រយោជន៍ខាងសុខភាព ដែលជាសិទ្ធិទូទៅរបស់ប្រជាជន។

**មាត្រា៦៣ .-**

ឱសថការីអាចផ្តល់ឱសថដល់អ្នកជំងឺដែលខ្លួនយល់ថាសមស្របនឹងការព្យាបាល ប៉ុន្តែជានិច្ចកាលត្រូវប្រាប់អ្នកជំងឺឱ្យទៅពិគ្រោះជាមួយគ្រូពេទ្យ។

**មាត្រា៦៤ .-**

ឱសថការីត្រូវធ្វើយ៉ាងណាកុំឱ្យគេស្គាល់ភិនភាគឬអត្តសញ្ញាណរបស់អ្នកជំងឺ នៅពេលដែលខ្លួនធ្វើការផ្សព្វផ្សាយឬធ្វើបទបង្ហាញជាសាធារណៈ។

## ជំពូកទី៥
## ឱសថការីនិងសហភាគៈ
## ឱសថការីនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត

**មាត្រា៦៥ ..**

ឱសថការីទាំងអស់ត្រូវមានទំនាក់ទំនងល្អជាមួយសហភាគៈជានិច្ច និងត្រូវគោរពគ្នាទៅវិញទៅមកដោយប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាពស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ជៀសវាងការវាយប្រហារសហភាគៈក្នុងបំណងប្រកួតប្រជែង។ ឱសថការីត្រូវចេះជួយសហភាគៈទៅវិញទៅមកពេលមានទុក្ខលំបាក។

ក្នុងករណីដែលមានទំនាស់វិជ្ជាជីវៈរវាងសហភាគៈ ត្រូវខិតខំសម្របសម្រួលដោយស្មារតីសាមគ្គីភាព។

**មាត្រា៦៦ ..**

ឱសថការីដែលគ្រប់គ្រងឱសថស្ថាន គ្រឹះស្ថានអាហារណនីហរណៈ គ្រឹះស្ថានផលិតឱសថ ត្រូវគាំទ្រ និងចាត់ទុកឱសថការីជំនួយការ ឬឱសថការីជំនួស ឬនិស្សិតឱសថសាស្ត្រឆ្នាំទី៥ជាសហភាគៈ ដោយមិនមានការរើសអើងអ្វីឡើយ។

**មាត្រា៦៧ ..**

ឱសថការីត្រូវគោរពនិងរក្សាទំនាក់ទំនងល្អជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ពិសេសបង្ហាញនូវកិច្ចសហការគ្នា ការផ្លាស់ប្តូរបទពិសោធ ការផ្តល់ព័ត៌មានដែលមានផលប្រយោជន៍ដល់សុខភាពមនុស្សក្នុងសង្គម។ ឱសថការីមិនត្រូវនិយាយឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ទោះបីជាសាធារណៈក្តី ជាឯកជនក្តី ដែលបង្កឱ្យមានការមិនសប្បាយចិត្តដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត។

**មាត្រា៦៨ ..**

ឱសថការីមិនត្រូវឃុបឃិតគ្នាជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ដើម្បីទាញយកផលប្រយោជន៍ដោយផ្ទាល់ឬដោយប្រយោល ដែលនាំឱ្យមានបន្ទុកដល់អ្នកជំងឺឬក្រុមគ្រួសាររបស់អ្នកជំងឺឡើយ។

## ជំពូកទី៦
## ទណ្ឌកម្មខាងវិន័យ

**មាត្រា៦៩ ..**

ឱសថការីដែលមិនគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យពីគណៈឱសថការីកម្ពុជា។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៧០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧១ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ